**LOWELL PUBLIC SCHOOLS**
Henry J. Mroz Central Administration Offices
155 Merrimack Street
Lowell, MA 01852

*ខាងក្រោមនេះគឺជាព័ត៌មានជីវប្រវត្តិអំពីបេក្ខជនវគ្គចុងក្រោយចំនួនបីរូបសម្រាប់មុខតំណែងនាយកសាលានៅ Lowell High School - Ian Charles, Michael Fiato និង Sara Pragluski Walsh។ ជីវប្រវត្តិទាំងនេះត្រូវបានបង្ហាញតាមលំដាប់អក្សរ៖*

## IAN CHARLES

Ian N. Charles បានចាប់ផ្តើមអាជីពការងារនៅក្នុងការអប់រំជាគ្រូបង្រៀនជំនួសរយ:ពេលវែងនៅឆ្នាំ 1998 ដោយបម្រើការងារនៅក្នុងសហគមន៍ Lowell Public School ក្នុងវិស័យអប់រំពិសេស មនុស្សសាស្ត្រ និងការសិក្សាសង្គម។ លោកបានធ្វើការនៅ Rogers, Robinson and Pyne Arts ខណ:ពេលកំពុងសិក្សានៅសកលវិទ្យាល័យ University of Massachusetts នៅ Lowell នាពេលល្ងាច។ លោកគឺជាពលរដ្ឋរបស់ Lowell ក្នុងអំឡុងពេលដែលលោកស្ថិតនៅក្នុងមណ្ឌលនេះ។ កូនៗរបស់លោកបានចូលរៀននៅ Pyne Arts School បន្ទាប់ពីត្រឡប់មកពី Florida ដែលលោកបានបន្តអាជីពរបស់ខ្លួននៅក្នុងការអប់រំនៅ Olympia High School ជាគ្រូបង្រៀនប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច។ បន្ទាប់មកលោកបានត្រឡប់មក Massachusetts ដែលលោកបានបម្រើការងារជាគ្រូបង្រៀនវិទ្យាសាស្ត្រសង្គមនៅ Peabody Middle School នៅ Cambridge។ ខណ:ពេលធ្វើការនៅ Peabody Middle School លោក Ian Charles បានចូលរៀននៅមហាវិទ្យាល័យ Cambridge College នៅពេលល្ងាច ស្របពេលដែលលោកបានបន្តអាជីពការងារនៅក្នុងផ្នែករដ្ឋបាលអប់រំ។ លោកបានទទួលការងារជាជំនួយការនាយកបណ្តោះអាសន្ននៅ Healy Middle School នៅ Somerville។ លោកបានទទួលមុខតំណែងអចិន្ត្រៃយ៍ជាជំនួយការនាយករបស់ Winter Hill Community Innovation School។

បន្ទាប់មកលោកបានទទួលការងារនៅ Medford ដើម្បីជួយដឹកនាំ McGlynn Middle School។ ការងារដ៏អស្ចារ្យរបស់លោកក្នុងនាមជាអ្នកដឹកនាំផ្នែកអប់រំបានទទួលការចាប់អារម្មណ៍ពីសហគមន៍ Medford Public School និងរដ្ឋបាលមណ្ឌល។ លោកត្រូវបានតែងតាំងជាជំនួយការនាយកនៃ Medford High school ដែលលោកត្រួតពិនិត្យលើការផ្លាស់ប្តូរដោយជោគជ័យនៃថ្នាក់សិស្សថ្មីដែលមានសិស្សជាង 325 នាក់។ ការងាររបស់លោកបានទទួលការចាប់អារម្មណ៍ពី Charter School នៅ Dorchester ដែលក្រោយមកលោកបានបម្រើការងារជានាយកសាលា Codman Academy។

Ian Nigel Charles បានទទួលបរិញ្ញាបត្រ (B.A.) ក្នុងផ្នែកគោលនយោបាយសាធារណ: និងរដ្ឋបាលដោយផ្តោតលើវិទ្យាសាស្ត្រនយោបាយមកពី University of Massachusetts នៅថ្នាក់ Lowell ឆ្នាំ ’99។ លោក Charles ក៏មានសញ្ញាបត្រអនុបណ្ឌិតអប់រំ (M.Ed.) ផ្នែកកម្មវិធីសិក្សា និងការបង្រៀនមកពី University of Massachusetts នៅថ្នាក់ Lowell ឆ្នាំ ’02 ផងដែរ។ លោកក៏មានវិញ្ញាបនបត្រនៃការសិក្សាថ្នាក់ឧត្តមកម្រិតខ្ពស់ (Certificate of Advance Graduate Study; C.A.G.S.) មកពី Cambridge College ថ្នាក់ឆ្នាំ ’11 ដោយផ្តោតលើគោលនយោបាយរដ្ឋបាល និងការធ្វើកំណែទម្រង់សាលារៀនផងដែរ។ បច្ចុប្បន្ននេះ Ian N. Charles គឺជាបេក្ខភាពបណ្ឌិតនៅ College of Professional Studies នៃសកលវិទ្យាល័យ Northeastern នៅក្នុងផ្នែកភាពជាអ្នកដឹកនាំរដ្ឋបាល។ លោកមានវិញ្ញាបនបត្រនៅក្នុងភាពជាអ្នកដឹកនាំអប់រំសម្រាប់ថ្នាក់ទី 5-12 នៅ Massachusetts។ លោកក៏មានវិញ្ញាបនបត្រជានាយកសាលាសម្រាប់ថ្នាក់ k-12 នៅ Massachusetts ផងដែរ។

## MICHAEL FIATO

Michael Fiato គឺជាអ្នកអប់រំដែលស្រលាញ់ការងារខ្លាំង និងមានចក្ខុវិស័យវែងឆ្ងាយជាមួយ បទពិសោធន៍ជាង 20 ឆ្នាំនៅក្នុងវិស័យអប់រំសាធារណៈ។ បច្ចុប្បន្ន Michael បម្រើការងារជា ជំនួយការអ្នកគ្រប់គ្រងមានគោលដៅ (Targeted Assistance Manager) សម្រាប់ប្រព័ន្ធ គាំទ្រទូទាំងរដ្ឋនៅនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សា។ Michael ចាប់ដៃគូជាមួយ សាលារៀន និងមណ្ឌលដែលមានសាលារៀនដែលត្រូវបានកំណត់ថាត្រូវការជំនួយ និងការអន្តរាគមន៍នៅលើប្រព័ន្ធគណនេយ្យភាពរដ្ឋ។

មុនពេលចូលធ្វើការជាមួយ DESE លោក Michael បានបម្រើការងារជានាយកសាលា Lawrence High School និងមានបទពិសោធន៍យ៉ាងទូលំទូលាយអំពីការកែលម្អសាលារៀន ការរចនា ឡើងវិញ និងការអនុវត្តបង្វិលស្ថានការណ៍នៅកម្រិតមធ្យមសិក្សា។ នៅក្នុងតួនាទីរបស់លោក ជានាយកសាលា លោក Michael មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត កម្មវិធីមហាវិទ្យាល័យរហ័ស និងមាគ៌ាអាជីពសម្រាប់សិស្ស។ ម៉ូដែលនេះរាប់បញ្ចូលកម្មវិធី ហាត់ការ 2 ដែលចាប់ដៃគូជាមួយវិស័យសាធារណៈ និងឯកជន និងការអភិវឌ្ឍមាគ៌ាអាជីព ដែលសិស្សមានឱកាសស្វែងយល់ស៊ីជម្រៅអំពីប្រធានបទដែលទាក់ទងនឹងឧស្សាហកម្ម និង អាជីពជាក់លាក់។ បានជំរុញដោយជំនឿថាសិស្សទាំងអស់គួរតែទទួលបានកម្មវិធីសិក្សា និងបំពាក់បំប៉នដែលមានគុណភាពខ្ពស់ លោកក៏បានពង្រីកឱកាសតាមរយៈការផ្តល់មូលនិធិ និងការគាំទ្រកាន់តែប្រសើរសម្រាប់មុខវិជ្ជាភាពយន្ត តន្ត្រី និងសិល្បៈ។

មុនពេលបម្រើការងារជានាយកសាលា Michael បានបំពេញតួនាទីជានាយកសាលាវិទ្យាល័យ មួយក្នុងចំណោមវិទ្យាល័យប្រាំមួយនៅ Lawrence High រយៈពេលប្រាំបីឆ្នាំ។ ក្នុងអំឡុងពេលនោះ សាលារៀនរបស់គាត់បានបង្កើនអត្រាបញ្ចប់ការសិក្សា និងបានកាត់បន្ថយអត្រាសិស្ស បោះបង់ការសិក្សា និងកែលម្អលទ្ធផលការសិក្សាយ៉ាងខ្ជាប់ខ្ជួននៅលើប្រព័ន្ធគណនេយ្យភាព ទូទាំងរដ្ឋ។ នៅក្នុងអាជីពការងាររបស់លោក Michael បានបម្រើតួនាទីជាច្រើនដូចជា ព្រឹទ្ធបុរសសិក្សា គ្រូបង្វឹកអត្តពលកម្ម រដ្ឋបាលការសិក្សា នាយក និងនាយកសាលា។ Michael ទាញយកចំណង់ចំណូលចិត្តរបស់ខ្លួនសម្រាប់ការអប់រំសាធារណៈ សមភាព និងយុត្តិធម៌សង្គមពី ឫសគល់របស់លោកនៅក្នុងការរៀបចំសហគមន៍ និងការអភិវឌ្ឍយុវជននៅក្នុងដំណាក់ កាលដំបូងនៃអាជីពការងាររបស់លោក។ លោកជឿជាក់យ៉ាងមុតមាំថា សាលាវិទ្យាល័យ គួរតែធ្វើឲ្យប្រាកដថាសិស្សទាំងអស់បញ្ចប់ការសិក្សាដោយមានជំហានបន្ទាប់ដ៏មានកិត្តិយស នៅក្នុងទម្រង់នៃផែនការក្រោយថ្នាក់មធ្យមសិក្សាដែលរុញច្រានឲ្យពួកគេ ឈានទៅដល់ជោគជ័យនៅក្នុងសតវត្សរ៍ទី 21 នេះ។

## SARA PRAGLUSKI WALSH

Sara Pragluski Walsh, Ed.D បច្ចុប្បន្នបម្រើការជានាយកសាលា Algonquin Regional High School (ARHS)។ លោកស្រីមានអាជ្ញាប័ណ្ណផ្នែកបង្រៀនក្នុងមុខវិជ្ជាជីវវិទ្យា និងគណិតវិទ្យា ដោយមានការផ្តោតទៅលើសរីរវិទ្យា។ Dr. Walsh បានបន្តពង្រីកអាជីពការងារអប់រំប្រកបដោយវិជ្ជាជីវៈរបស់ខ្លួនតាមរយៈតួនាទីរបស់លោកស្រីជានាយករង ជំនួយការនាយក និងនាយកសាលាសម្រាប់ Springfield Public Schools។

Dr. Walsh បានទទួលការលូតលាស់ដោយមានវិជ្ជាជីវៈជំនាញតាមរយៈការងាររបស់លោកស្រីជាអ្នកគ្រប់គ្រងការរៀបចំកាលវិភាគសម្រាប់អគារ ដែលផ្តល់ឱកាស និងការចូលប្រើកាន់តែច្រើនដើម្បីឲ្យសិស្សចុះឈ្មោះចូលរៀនក្នុងមុខវិជ្ជាកម្រិតខ្ពស់។ អ្នកស្រីក៏បានធ្វើការជាមួយ Turn Around and Sustainability Practices តាមរយៈនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សា (DESE) ដែលឈ្នះរង្វាន់ក្នុងអំឡុងពេលនោះសម្រាប់ការរីកចម្រើនគួរឲ្យកត់សម្គាល់នៅលើសូចនាករសំខាន់ៗ និងការរីកចម្រើនទូទាំងសាលារៀនទាំងមូល។

លោកស្រីបានតម្រង់ក្តីស្រលាញ់នៃការសិក្សារបស់លោកស្រីដោយទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកភាពជាអ្នកដឹកនាំអប់រំ និងការគ្រប់គ្រងពី American International College និងកាន់សញ្ញាបត្រអនុបណ្ឌិតវិទ្យាសាស្ត្រជំនាញសរីរវិទ្យាលំហាត់ប្រាណមកពី University of Massachusetts Amherst។

ក្នុងនាមជាអ្នកដឹកនាំ Dr. Walsh ត្រូវបានពណ៌នាថាជាអ្នកដឹកនាំដែលមានថាមពល អ្នកដែលកំណត់ និងយកការរំពឹងទុកខ្ពស់ ខណៈដែលគាំទ្រអ្នកដទៃឲ្យសម្រេចបាននូវអ្វីលើសពីការរំពឹងទុករបស់ពួកគេ។ លោកស្រីពិតជាជឿជាក់ និងស្រលាញ់ចូលចិត្តខ្លាំងលើការលើកកម្ពស់អ្នកដទៃជាមួយការអប់រំ និងយកគំរូជាអ្នកសិក្សាពេញមួយជីវិត។ Dr. Walsh មានការប្តេជ្ញាចិត្ត និងជំរុញទឹកចិត្តខ្ពស់ដើម្បីនាំយកបទពិសោធន៍ផ្នែកសិក្សាដ៏ល្អប្រសើរទៅកាន់ភាគីពាក់ព័ន្ធទាំងអស់ ហើយមិត្តរួមការងាររបស់លោកស្រីកោតសរសើរពីសមត្ថភាពរបស់លោកស្រីក្នុងការសហការ ចូលរួម និងជំរុញ ក៏ដូចជាទំនាក់ទំនងដោយជោគជ័យ។

សិល្បៈ និងសកម្មភាពក្រៅកម្មវិធីសិក្សាមានសារៈសំខាន់ដូចគ្នា ដើម្បីអភិវឌ្ឍបទពិសោធន៍ការសិក្សាដ៏ល្អប្រសើរ ដែលលោកស្រីបង្ហាញតាមរយៈការស្រលាញ់ចូលចិត្តខ្លាំងរបស់ខ្លួន។ Dr. Walsh មានក្តីស្រលាញ់ពេញមួយជិតសម្រាប់សិល្បៈ ដែលលោកស្រីនិយាយពីបទពិសោធន៍ដ៏អស្ចារ្យរបស់ខ្លួនក្នុងនាមជាសិស្សនៅក្នុងថ្នាក់សិល្បៈ វង់តន្ត្រី និងក្រុមព្យុះហយាត្រា លោកស្រីធ្វើការជំរុញកូនៗផ្ទាល់របស់លោកស្រីជាមួយក្តីស្រលាញ់ដូចគ្នានេះ។

លោកស្រីថ្លែងថាជោគជ័យជាច្រើនរបស់លោកស្រីគឺបានមកពីបទពិសោធន៍ដ៏អស្ចារ្យក្នុងនាមជាសិស្សម្នាក់នៅ Springfield Public Schools តាមរយៈចម្រុះភាព ការគាំទ្រ និងឱកាស។ បទពិសោធន៍នេះបាននាំលោកស្រីត្រឡប់មកបង្រៀន និងដឹកនាំនៅស្រុកកំណើតរបស់ខ្លួនក្នុងអំឡុងផ្នែកដំបូងនៃអាជីពការងារអប់រំរបស់លោកស្រី។ ការចាប់អារម្មណ៍របស់លោកស្រីទៅលើសរីរវិទ្យា និងគណិតវិទ្យាបានជួយជុសខាត់ការបណ្តុះបណ្តាលអត្តពលកម្មរបស់លោកស្រី ដែលលោកស្រីគឺជាអត្តពលិកហាត់ World Class Ironman បីលើកដែលបានចូលនិវត្តន៍ អ្នកចូលរួមប្រកួតដប់លើក ព្រមទាំងជាអ្នករត់ម៉ារ៉ាតុង និងអ៊ុលត្រាម៉ារ៉ាតុងដែលបានឈ្នះរង្វាន់ផងដែរ។

ជាចុងក្រោយ Dr. Walsh ទន្ទឹងរង់ចាំឱកាសដែលបានបង្ហាញជារៀងរាល់ថ្ងៃដើម្បីក្លាយជាផ្នែកមួយនៃការសិក្សា និងដឹកនាំការសិក្សាតាមបែបបទមួយដែលមានសុវត្ថិភាព មានការសហការ និងមានការរាប់បញ្ចូល។